# កំណត់សំគាល់ ផ្នែកច្បាប់
# ស្តីពី
# ការអនុវត្តភាតព្វកិច្ចតាមច្បាប់ របបសន្តិសុខសង្គម ផ្នែកប្រាក់សោធន
# សម្រាប់ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ( NGOs )

## ប្រវត្តិ

ព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ ២០១៩ ប្រកាសឲ្យប្រើច្បាប់ស្តីពី របបសន្តិសុខសង្គម មានគោលដៅ ៖ កំណត់អំពីគោលការណ៍ទូទៅ បែបបទ យន្តការអនុវត្ត និងប្រព័ន្ធគ្រប់គ្រងរបបសន្តិសុខសង្គមនៃព្រះរាជាណាចក្រកម្ពុជា ដែលរួមមាន ផ្នែកប្រាក់សោធន ផ្នែកថែទាំសុខភាព ផ្នែកហានិភ័យការងារ និងផ្នែកនិកម្មភាពការងារ។[1]

អនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី ០៤ ខែមីនា ឆ្នាំ ២០២១ ស្តីពី របបសន្តិសុខសង្គមផ្នែកប្រាក់សោធនមានគោលបំណង៖ ដាក់ឲ្យដំណើរការរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ តាមរយៈការកំណត់យន្តការលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការចុះបញ្ជី ការបង់ភាគទាន អត្រាភាគទាន អត្រាសមាច័យ ការទាមទារ និងការផ្តល់តាវកាលិក ។[2]

ប្រកាសអន្តរក្រសួងលេខ ១៦៥/២២ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០២២ ស្តីពី ការដាក់ឲ្យអនុវត្តរបបផ្នែកប្រាក់សោធន រវាង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ មានគោលបំណង ៖ កំណត់កាលបរិច្ឆេទសម្រាប់ការអនុវត្តរបបសន្តិសុខសង្គម

---

[1] មាត្រា ១ នៃច្បាប់ស្តីពី របបសន្តិសុខសង្គម ឆ្នាំ ២០១៩

[2] មាត្រា ១ អនុក្រឹត្យលេខ ៣២ អនក្រ.បក ឆ្នាំ ២០២១

ផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដូចមានចែងក្នុងមាត្រា ៣៩ នៃអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី ០៤ ខែមីនា ឆ្នាំ ២០២១។[3]

ប្រកាសលេខ ១៦៨/២២ ក.ប/ប្រ.ក.ប.ស.ស របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី ០៥ខែកក្កដា ឆ្នាំ២០២២ មានគោលបំណង៖ កំណត់អំពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិតនិងការបង់ភាគទាន សម្រាប់បុគ្គលទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ក្នុងបេឡាជាតិសន្តិសុខសង្គម ដែលសរសេរជាអក្សរកាត់ថា ប.ស.ស. ដើម្បីធានាបានប្រសិទ្ធភាព និងបង្កលក្ខណៈងាយស្រួល ដល់ការអនុវត្តរបបសន្តិសុខសង្គម ។[4]

ប្រកាសលេខ ១៦៩/២២ ក.ប/ប្រ.ក.ប.ស.ស របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី ០៥ខែកក្កដា ឆ្នាំ២០២២ មានគោលបំណង៖ កំណត់បែបបទ និងនីតិវិធីនៃការផ្តល់វិភាជន៍បូជាសពនៃរបបសន្តិសុខសង្គម ផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដើម្បីធានាបាននូវប្រសិទ្ធភាព និងប្រសិទ្ធផលនៃការអនុវត្តរបបសន្តិសុខសង្គម ។[5]

ប្រកាសលេខ ១៧០/២២ ក.ប/ប្រ.ក.ប.ស.ស របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី ០៥ខែកក្កដា ឆ្នាំ២០២២ មានគោលបំណង៖ កំណត់អំពីកាលបរិច្ឆេទនៃការចាប់ផ្តើមបង់ភាគទាន ជាកាតព្វកិច្ច និងរបបភាគទានដោយស្ម័គ្រចិត្ត ដូចមានចែងក្នុងមាត្រា៣៣ នៃអនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី ០៤ ខែមីនា ឆ្នាំ ២០២១ ។[6]

## កាតព្វកិច្ចអនុវត្តផ្នែកប្រាក់សោធនសម្រាប់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល

### ១.ដំណើរការអនុវត្តរបបសន្តិសុខសង្គម

ការកំណត់អំពីគោលការណ៍ទូទៅ បែបបទយន្តការអនុវត្ត និងប្រព័ន្ធគ្រប់គ្រងរបបសន្តិសុខសង្គមនៃព្រះរាជាណាចក្រកម្ពុជា រួមមាន ផ្នែកប្រាក់សោធន ផ្នែកថែទាំសុខភាព ផ្នែកហានិភ័យការងារ និងផ្នែកនិកម្មភាពការងា[7]។

ការអនុវត្តរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាពជំហានទី២ ត្រូវបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល ហើយត្រូវបង្កើតឡើងដោយអនុក្រឹត្យលេខ

[3] ប្រការ ១ ប្រកាសអន្តរក្រសួងលេខ ១៦៥/២២ ក.ប/ប្រ.ក.ប.ស.ស

[4] ប្រការ ១ ប្រកាសលេខ ១៦៨/២២ ក.ប/ប្រ.ក.ប.ស.ស ឆ្នាំ ២០២២

[5] ប្រការ ១ ប្រកាសលេខ ១៦៩/២២ ក.ប/ប្រ.ក.ប.ស.ស ឆ្នាំ ២០២២

[6] ប្រការ ១ ប្រកាសលេខ ១៧០/២២ ក.ប/ប្រ.ក.ប.ស.ស ឆ្នាំ ២០២២

[7] មាត្រា ២ ច្បាប់ស្តីពី របបសន្តិសុខសង្គម ឆ្នាំ ២០១៩

០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

របបសន្តិសុខសង្គម ផ្នែកហានិភ័យការងារជំហានទី១ ត្រូវបានដាក់អោយអនុវត្តដោយប្រកាសលេខ ០២២/០៨ កប-ប្រក របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពី ការកំណត់ដំណាក់កាល និងវិសាលភាពនៃការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ និងបន្តអនុវត្ត តាមប្រកាសលេខ ១០៩ កប-ប្រក របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ។

របបសន្តិសុខសង្គមផ្នែកប្រាក់សោធនបានដាក់អោយដំណើរការដោយអនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី ០៤ ខែមីនា ឆ្នាំ ២០២១ ស្តីពី របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ។ នៅខែសីហា ឆ្នាំ ២០២២ របបសន្តិសុខសង្គម ផ្នែកប្រាក់សោធន ត្រូវបានដាក់អោយដំណើរការដោយប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធជាច្រើន ។

របបសន្តិសុខសង្គម ផ្នែកនិកម្មភាពការងារ គឺសំដៅដល់វេលាដែលបុគ្គលជាសមាជិក បសស មិនមានសកម្មភាពការងារដែលមានប្រាក់ចំណូល ឬទំនេរពីការងារ ដោយសារការបញ្ចប់ កិច្ចសន្យាការងារ ហើយសាមីជនបានស្វះស្វែងរកការងារ ក្នុងរយៈពេលមួយស្របតាមការកំណត់នៃច្បាប់ ឬបទបញ្ញាត្តិ បន្ទាប់ពីនិកម្មភាព។[8] របបសន្តិសុខសង្គម ផ្នែកនិកម្មភាពការងារ មិនទាន់មានលិខិតបទដ្ឋានសម្រាប់ដាក់អោយដំណើរការពេញលេញនៅឡើយទេ គឺតត្រឹម ខែ តុលា ឆ្នាំ ២០២២ នេះ។

## ២.ការចុះបញ្ជី ផ្នែកប្រាក់សោធន

របបសន្តិសុខសង្គមផ្នែកប្រាក់សោធនប្រកាសអោយអនុវត្តចាប់ពីថ្ងៃទី ១ខែកក្កដា ឆ្នាំ២០២២[9] និង បានកំណត់កាលបរិច្ឆេទនៃការចាប់ផ្តើមបង់ភាគទានជាកាតព្វកិច្ច និងរបបភាគទានដោយស្ម័គ្រចិត្តអនុវត្តចាប់ពីថ្ងៃទី ០១ ខែតុលា ឆ្នាំ ២០២២ តទៅ ។[10]

### ២.១.ការចុះបញ្ជីរបបភាគទានជាកាតព្វកិច្ច

និយោជកឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលប្រើប្រាស់កម្មករនិយោជិតចាប់ពី១(មួយ) នាក់ឡើង ត្រូវមានកាតព្វកិច្ចចុះបញ្ជីក្នុង **បសស** ផ្នែកប្រាក់សោធន ស្របតាមអនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី ០៤ ខែមីនា ឆ្នាំ ២០២១ ។

សមាជិក **បសស** ដែលបានចុះបញ្ជីផ្នែកថែទាំសុខភាព និងផ្នែកហានិភ័យការងាររួចហើយ

---

[8] ចំនុចលេខ ២១ នៃឧបសម្ព័ន្ធច្បាប់ស្តីពី របបសន្តិសុខសង្គម ឆ្នាំ ២០១៩

[9] ប្រការ ២ ប្រកាសលេខ ១៦៥/២២ ក.ប/ប្រ.ក.ប.ស.ស ឆ្នាំ ២០២២

[10] ប្រការ ២ ប្រកាសលេខ ១៧០/២២ ក.ប/ប្រ.ក.ប.ស.ស ឆ្នាំ ២០២២

និងត្រូវបន្ថែមការចុះបញ្ជី និងបង់ភាគទានដោយស្វ័យប្រវត្តិ ផ្នែកប្រាក់សោធន ។

ការចុះបញ្ជីកម្មករនិយោជិតជាសមាជិក **បសស** ត្រូវអនុទ្បោមតាមទិន្នន័យក្នុងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនសម្រាប់កម្មករនិយោជិតបរទេស ។[11]

### ២.២.ការចុះបញ្ជីរបបភាគទានដោយស្ម័គ្រចិត្ត

សមាជិក បសស ដែលបានបំពេញលក្ខខណ្ឌណាមួយដូចខាងក្រោម មានសិទ្ធិស្នើសុំមក **បសស.** ដើម្បីចូលរួមក្នុងផ្នែកប្រាក់សោធនតាម របបភាកទានដោយស្ម័គ្រចិត្ត ៖

១.បាត់បង់ការងារដែលមានប្រាក់ឈ្នួលមុនអាយុ ៦០(ហុកសិប)ឆ្នាំ និងមានលទ្ធភាពបង់ភាគទានបន្ត។

២.មានអាយុ ៦០(ហុកសិបឆ្នាំ) និងមានបំណងបង់ភាគទានបន្តដើម្បីទទួលបានសោធនជរាភាពខ្ពស់ជាងសោធនជរាភាពជាក់ស្តែងដែលសាមីជនត្រូវទទួលបាន តាមរបបភាគទានជាកាតព្វកិច្ច ។

៣.មានប្រាក់ចំណូលខ្ពស់ជាងប្រាក់ឈ្នួលពិតាន ដែលសាមីជនជាប់កាតព្វកិច្ចក្នុងរបបភាគទានជាកាតព្វកិច្ច ។ ប្រាក់ឈ្នួលពិតានប្រែប្រួលទៅតាមស្ថានភាពសេដ្ឋកិច្ច ដែលត្រូវកំណត់ដោយអនុក្រឹត្យ។

សមាជិក **បសស.** អាចស្នើសុំចុះបញ្ជី ផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តនៅ**បសស.** ដោយសាមីជនផ្ទាល់ ។[12]

## ៣.អត្រាភាគទានប្រាក់សោធន

ប្រាក់ឈ្នួលជាប់ភាគទានអប្បបរមាត្រូវកំណត់ស្មើនឹងចំនួន ៤០០ ០០០(បួនសែន) រៀល និងប្រាក់ឈ្នួលជាប់ភាគទានពិតានស្មើនិងចំនួន ១ ២០០ ០០០(មួយលានពីរសែន)រៀល ។

ប្រាក់ឈ្នួលជាប់ភាគទានគឺជាប្រាក់ឈ្នួលរបស់កម្មករនិយោជិតដែលតម្រូវអោយជាប់ភាគទានតាមច្បាប់ ឬប្រាក់ធនលាភរបស់កម្មករនិយជិត ដែលបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ចាប់ពី ២០%(ម្ភៃភាគរយ) ឡើង ឬប្រាក់សោធនរបស់កម្មករនិយោជិត ដែលតម្រូវអោយជាប់ភាគទានផ្នែកថែទាំសុខភាព ។

ការកែសម្រួលកម្រិតអប្បបរមា និងពិដាន នៃប្រាក់ឈ្នួលជាប់ភាគទានត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុម ប្រឹក្សាភិបាលនៃ **បសស.**[13] ។

### ៣.១.អត្រា របបភាគទានជាកាតព្វកិច្ច

---

[11] មាត្រា៥,៦ នៃអនុក្រឹត្យលេខ ៣២ អនក្រ.បក ឆ្នាំ ២០២១

[12] មាត្រា១៨,១៩ នៃអនុក្រឹត្យលេខ ៣២ អនក្រ.បក ឆ្នាំ ២០២១

[13] មាត្រា ៤ នៃអនុក្រឹត្យលេខ ១៩៤ អនក្រ.បក ឆ្នាំ ២០២១

អត្រាភាគទាននៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន ត្រូវបានកំណត់តាមវិធីសាស្ត្របុព្វលាភជណ្ដើរ ដូចខាងក្រោម ៖

- ដំណាក់កាលទី ១ ៖ ភាគទានត្រូវកំណត់ស្មើនឹង ៤ %(បួនភាគរយ) នៃប្រាក់ឈ្នួលជាប់ភាគទានក្នុងរយៈពេល ០៥ (ឆ្នាំ)ដំបូង ។
- ដំណាក់កាលទិ២ ៖ ភាគទានត្រូវកំណត់ស្មើនឹង ៨ %(ប្រាំបីភាគរយ) នៃប្រាក់ឈ្នួលជាប់ភាគទានក្នុងរយៈពេល ០៥ (ឆ្នាំ) បន្ទាប់ពីដំណាក់កាលទី ១ ។
- ដំណាក់កាលទី ៣ ៖ អត្រាភាគទានត្រូវដំឡើង ២.៧៥%(ពីរក្បៀសចិតសិបប្រាំភាគរយ)នៃប្រាក់ឈ្នួលជាប់ភាគទាន ឬប្រាក់ស្មើសុំជាប់ភាគទាន ក្នុងរយៈពេល ១០(ដប់)ឆ្នាំ និងដំណាក់កាល១០(ដប់)ឆ្នាំ បន្តបន្ទាប់ ។[14]

ភាគទានផ្នែកប្រាក់សោធនជាកាតព្វកិច្ច ជាបន្ទុករួមគ្នារវាងនិយោជកឬម្ចាស់សហគ្រាគ្រឹះស្ថាន និងកម្មករនិយោជិត។ សម្រាប់រយៈពេល ០៥ ឆ្នាំដំបូងភាគទាននេះត្រូវកំណត់ក្នុងអត្រាស្មើនឹង ៤%(បួនភាគរយ) នៃប្រាក់ឈ្នួលជាប់ភាគទាន ដូចបានកំណត់ដូចខាងក្រោម ៖

- ២%(ពីរភាគរយ) ជាបន្ទុកនិយោជក់
- ២%(ពីរភាគរយ) ជាបន្ទុកកម្មករ និយោជិត ។

ប្រាក់ឈ្នួលប្រចាំខែត្រូវគិតជាប្រាក់រៀល បើប្រាក់ឈ្នួលជារូបិយបណ្ណបរទេសត្រូវគិតជាប្រាក់រៀលតាម អត្រាប្តូរប្រាក់ជាមធ្យមប្រចាំខែ ដោយផ្អែកតាមអត្រាប្តូរប្រាក់ ធនាគារជាតិនៃកម្ពុជា ដែលជូនដំណឹងដោយ **បសស**. ។ ប្រាក់ឈ្នួលជាប់ភាគទានត្រង់ចំនុចនេះ និងត្រូវកំណត់ដោយអនុក្រឹត្យ ដោយឡែក។[15]

ការបង់ភាគទានផ្នែកប្រាក់សោធនត្រូវធ្វើឡើងជាប្រចាំខែ ។ និយោជកឬម្ចាស់សហគ្រាគ្រឹះស្ថានទាំងអស់ត្រូវមានកាតព្វកិច្ចប្រមូលនិងបង់ភាគទានដែលជាចំណែករបស់ខ្លួន និងជាចំណែករបស់កម្មករនិយោជិត មកក្នុងគណនី **បសស**.នៅធនាគារដៃគូរ យ៉ាងយូរត្រឹម ថ្ងៃទី ១៥ (ដប់ប្រាំ)នៃខែបន្ទាប់។

ក្នុងករណីនិយោជកឬម្ចាស់សហគ្រាគ្រឹះស្ថានមានលទ្ធភាពបង់ភាគទានប្រចាំឆ្នាំត្រូវស្នើសុំមក**បសស**. ។ ការបង់ភាគទានប្រចាំឆ្នាំនេះ ត្រូវធ្វើឡើងនៅខែបន្ទាប់គិតចាប់ពីកាលបរិច្ឆេទនៃខែដែលបានស្នើសុំបង់ភាគទាន។

ការបង់ភាគទានប្រចាំឆ្នាំត្រូវបង់តាមឆ្នាំនៃប្រតិទិន។**បសស**.ត្រូវធ្វើការកែតម្រូវចំនួនភាគទាននៅដើមឆ្នាំបន្ទាប់។[16]

### ៣.២.អត្រា របបភាគទានដោយស្ម័គ្រចិត្ត

---

[14] មាត្រា ៣៤ នៃអនុក្រឹត្យលេខ ៣២ អនក្រ.បក ឆ្នាំ ២០២១

[15] មាត្រា៨ នៃអនុក្រឹត្យលេខ ៣២ អនក្រ.បក ឆ្នាំ ២០២១

[16] មាត្រា៩ នៃអនុក្រឹត្យលេខ ៣២ អនក្រ.បក ឆ្នាំ ២០២១

ភាគទានផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តជាបន្ទុកផ្ទាល់របស់សាមីជនដែលបានចុះបញ្ជី ក្នុងផ្នែកនេះ។ អត្រាភាគទានផ្នែកនេះត្រូវកំណត់ស្មើនឹងអត្រាភាគទានតាមរបបភាគទានជាកាតព្វកិច្ច (៤% នៃប្រាក់ឈ្នួលជាប់ភាគទាន) ។ ចំនួនទឹកប្រាក់ជាប់ភាគទានត្រូវអនុវត្តតាមប្រាក់ស្នើសុំជាប់ភាគទានរបស់សាមីជនផ្ទាល់។

ប្រាក់ស្នើសុំជាប់ភាគទានសម្រាប់សមាជិក**បសស**. ដែលបាត់បង់ការងារមុនអាយុ ៦០ (ហុកសិប)ឆ្នាំ និង មានលទ្ធភាពបង់ភាគទានបន្ត ត្រូវកំណត់ស្មើនឹងប្រាក់ឈ្នួលមធ្យម ០៦(ប្រាំមួយ)ខែចុងក្រោយ គិតចាប់ចាប់ពីកាលបរិច្ឆេទបាត់បង់ការងារ ។

ចំពោះសមាជិក **បសស**. ដែលបានបំពេញលក្ខខណ្ឌក្នុងចំណុច (១.បាត់បង់ការងារដែលមានប្រាក់ឈ្នួលមុនអាយុ ៦០ឆ្នាំ និងមានលទ្ធភាពបង់ភាគទានបន្ត) ឬចំណុច (២.មានអាយុ ៦០ឆ្នាំនិងមានបំណងបង់ភាគទានបន្ត ដើម្បីទទួលបានសោធនជរាភាពខ្ពស់ជាងសោធនជរាភាពជាក់ស្តែងដែលសាមីជនត្រូវទទួលបានតាមរបបភាគទានជាកាតព្វកិច្ច) នៃមាត្រា ១៨ នៃអនុក្រឹត្យលេខ ៣២ អនក្រ.បក ឆ្នាំ ២០២១ ត្រូវអនុវត្តនីតិវិធីបង់ភាគទានក្នុងផ្នែកនេះយ៉ាងតិចចាប់ពី ០៦(ប្រាំមួយ) ខែឡើង។

ចំពោះសមាជិក **បសស**.ដែលបានបំពេញលក្ខខណ្ឌក្នុងចំណុច (៣.មានប្រាក់ចំណូលខ្ពស់ជាងប្រាក់ឈ្នួលពិតាន ដែលសាមីជនជាប់កាតព្វកិច្ចក្នុងរបបភាគទានជាកាតព្វកិច្ច) នៃមាត្រា ១៨ នៃអនុក្រឹត្យលេខ ៣២ អនក្រ.បក ឆ្នាំ ២០២១ ត្រូវអនុវត្តតាមប្រព័ន្ធហិរញ្ញប្បទានពេញលេញ។[17]

សមាជិក **បសស**. ដែលបានចូលរួមក្នុងរបបភាគទានដោយស្ម័គ្រចិត្តមានកាតព្វកិច្ចបង់ភាគទានដោយ ផ្ទេរតាមលេខអត្តសញ្ញាណសោធនស្ម័គ្រចិត្តដែលចេញដោយ**បសស**.មកក្នុងគណនី**បសស**.នៅធនាគារដៃគូរ។

## ៤.តាវកាលិកផ្នែកប្រាក់សោធន

### ៤.១.លក្ខខណ្ឌទទួលបានសោធនជរាភាព

សមាជិក **បសស**. មានសិទ្ធិទទួលបានសោធនជរាភាពត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១.បានចុះបញ្ជីក្នុងផ្នែកប្រាក់សោធន

២.មានអាយុយ៉ាងតិច ៦០(ហុកសិប)ឆ្នាំ និង

៣.បានបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិច ១២(ដប់ពីរ)ខែ។

សោធនជរាភាពដែលផ្តល់ឲ្យត្រូវគណនាតាមរូបមន្តដូចខាងក្រោម ៖

សជ = អស x បឈម

សជ ជាសោធនជរាភាពរបស់សាមីជនដែលត្រូវទទួលបាន

[17] មាត្រា២០ នៃអនុក្រឹត្យលេខ ៣២ អនក្រ.បក ឆ្នាំ ២០២១

អស	ជាអត្រាសោធនដែលត្រូវទទួលបានដូចមានកំណត់ក្នុងឧបសម្ព័ន្ធ ១ អនុក្រឹត្យ ៣២[18]។
បឈម	ជាប្រាក់ឈ្នួលមធ្យមដែលបានបង់ភាគទានរបស់សាមីជន ។

## សង្ខេប ឧបសម្ព័ន្ធ ១ នៃអនុក្រឹត្យលេខ ៣២ អនក្រ.បក ឆ្នាំ ២០២១

| ឆ្នាំ | អត្រាសោធន | រូបមន្ត |
|---|---|---|
| ១ | ១.៧៥% | ១ x ១.៧៥ % |
| ២ | ៣.៥០% | ២ x ១.៧៥ % |
| ៣ | ៥.២៥% | ៣ x ១.៧៥ % |
| ៤ | ៧.០០% | ៤ x ១.៧៥ % |
| | | |
| ១៥ | ២៦.២៥% | ១៥ x ១.៧៥ % |
| ១៦ | ២៧.៥០% | ១៥ x ១.៧៥ %+១ x១.២៥% |
| ១៧ | ២៨.៧៥% | ១៥ x ១.៧៥ %+២ x១.២៥% |
| ១៨ | ៣០.០០% | ១៥ x ១.៧៥ %+៣ x១.២៥% |
| | | |
| ៣០ | ៤៥.០០% | ១៥ x ១.៧៥ %+១៥ x១.២៥% |
| ៣១ | ៤៦.២៥% | ១៥ x ១.៧៥ %+១៦ x១.២៥% |
| ៣២ | ៤៧.៥០% | ១៥ x ១.៧៥ %+១៧ x១.២៥% |
| | | |
| ៤៨ | ៦៧.៥០% | ១៥ x ១.៧៥ %+៣៣ x១.២៥% |
| ៤៩ | ៦៨.៧៥% | ១៥ x ១.៧៥ %+៣៤ x១.២៥% |
| ៥០ | ៧០.០០% | ១៥ x ១.៧៥ %+៣៥ x១.២៥% |

ក្នុងករណីសមាជិក**បសស**. មិនបានបំពេញលក្ខខណ្ឌក្នុងចំណុចលេខ ៣ គឺបានបង់ភាគទានតិចជាង ១២ ខែ វិភាជន៍ជរាភាពត្រូវទូទាត់ផ្ដាច់តែមួយដង ដែលត្រូវគណនាតាមរូបមន្តដូចខាងក្រោម ៖

វភជ = ផភ(១+សជ)

[18] មើលលម្អិតក្នុងឧបសម្ព័ន្ធ ១ នៃអនុក្រឹត្យលេខ ៣២ អនក្រ.បក ឆ្នាំ ២០២១

| | |
|---|---|
| វភជ | ជាវិភាជន៍ជរាភាពរបស់សាមីជនដែលត្រូវទទួលបាន |
| សផ | ជាសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ផ្លូវការ |
| ផភ | ជាផលបូកចំនួនភាគទានដែលបានបង់សម្រាប់របបប្រាក់សោធន ។[19] |

## ៤.២.លក្ខខណ្ឌទទួលបានសោធនទុព្វលភាព

ទុព្វលភាព សំដៅដល់ការបាត់បង់សមត្ថភាពការងារ ដែលមិនបណ្ដាលមកពីហានិភ័យការងារ។ ងាច ត្រូវចាត់ទុកជាជនដែលទទួលរងទុព្វលភាព លុះត្រាតែសាមីជន ជាសមាជិក បសស. មានជំងឺ ឬរងភាពពិការ នាំឲ្យ អស់សមត្ថភាពរកប្រាក់ចំណូល ឬរកបានប្រាក់ចណូលទាបជាងចំណូលដែលកំណត់ក្នុងខ្សែបន្ទាត់ក្រីក្ររបស់ ព្រះរាជាណាចក្រកម្ពុជា ។[20]

សមាជិក**បសស.** ដែលធ្លាក់ខ្លួនទុព្វលភាព មានសិទ្ធិទទួលបានសោធនទុព្វលភាពប្រសិនបើសាមីជន បានបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

១.បានចុះបញ្ជីក្នុងផ្នែកប្រាក់សោធន

២.បានបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិច ៦០(ហុកសិប)ខែ មុនកាលបរិច្ឆេទទទួលរងទុព្វលភាព។

សោធនទុព្វលភាពត្រូវគណនាតាមរូបមន្តខាងក្រោម ៖

សទ = អស x បឈម

| | |
|---|---|
| សទ | ជាសោធនទុព្វលភាពរបស់សាមីជនដែលត្រូវទទួលបាន |
| អស | ជាអត្រាសោធនដែលត្រូវទទួលបានដូចមានកំណត់ក្នុងឧបសម្ព័ន្ធ១ នៃអនុក្រឹត្យ លេខ ៣២ អនក្រ.បក ឆ្នាំ ២០២១ ។ |
| បឈម | ជាប្រាក់ឈ្នួលមធ្យមដែលបានបង់ភាគទានរបស់សាមីជន ។ |

កម្រិតអប្បបរមានៃសោធនទុព្វលភាពត្រូវកំណត់ស្មើនឹង ៤៥%(សែសិបប្រាំ)ភាគរយ នៃប្រាក់ឈ្នួល មធ្យមបង់ភាគទានរបស់សាមីជន ។[21]

ក្រុមប្រឹក្សាវេជ្ជសាស្ត្រ **បសស.** ត្រូវមានភារកិច្ចក្នុងការវាយតម្លៃ ឬសម្រេចអំពីស្ថានភាពទុព្វលភាព ។

## ៤.៣.លក្ខខណ្ឌទទួលបានសោធនឧត្តរជីវី

សោធនឧត្តរជីវី សំដៅដល់ប្រាក់សោធនដែលត្រូវផ្ដល់ជូនបុគ្គលនៅក្នុងបន្ទុកផ្ទាល់នៃសោធនិក ជរាភាព ឬទុព្វលភាព ឬសមាជិក**បសស.**ដែលបានបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិច ៥(ប្រាំ)ឆ្នាំ ទទួលមរណៈភាព។[22]

---

[19] មាត្រា១៣ នៃអនុក្រឹត្យលេខ ៣២ អនក្រ.បក ឆ្នាំ ២០២១

[20] ចំនុចលេខ ១៨ នៃឧបសម្ព័ន្ធច្បាប់ស្ដីពី របបសន្តិសុខសង្គម ឆ្នាំ ២០១៩

[21] មាត្រា១៤ នៃអនុក្រឹត្យលេខ ៣២ អនក្រ.បក ឆ្នាំ ២០២១

[22] ចំណុចលេខ ៤២ នៃឧបសម្ព័ន្ធ ច្បាប់ស្ដីពី របបសន្តិសុខសង្គម ឆ្នាំ ២០១៩

ឧត្តរជីវី សំដៅដល់បុគ្គលដែលនៅរស់ក្នុងបន្ទុកផ្ទាល់នៃសមាជិក **បសស**.មុនកាលបរិច្ឆេទដែលសាមីជន បានទទួលមរណភាពស្របតាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងបទប្បញ្ញត្តិនៃច្បាប់ស្តីពី របបសន្តិសុខសង្គម។[23]

សិទ្ធិវន្តនៃសោធនឧត្តរជីវី មានសិទ្ធិទទួលបានសោធនឧត្តរជីវីលុះត្រាតែ ៖

១.មានការទទួលមរណភាពនៃសាមីជនជាសោធនិកជរាភាព ឬទុព្វលភាព ឬសមាជិក **បសស**.

២. បានបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិច ៦០(ហុកសិប) ខែ ។

សោធនឧត្តរជីវីត្រូវគណនាតាមរូបមន្តខាងក្រោម ៖

| | | |
|---|---|---|
| សជវ | = | ៤៥% x សជ  ឬ  ៤៥% x សទ |
| សជវ | | ជាសោធនឧត្តរជីវីដែលសិទ្ធិវន្តត្រូវទទួលបាន |
| សជ | | ជាសោធនជរាភាព |
| សទ | | ជាសោធនទុព្វលភាព ។ |

ចំណែកសោធនឧត្តរជីវី ត្រូវបានបែងចែកដូចខាងក្រោម ៖

- សម្រាប់សហព័ទ្ធ  ៥០%(ហាសិបភាគរយ)
- សម្រាប់កូន ៥០%(ហាសិបភាគរយ)

ក្នុងរណីដែលសិទ្ធិវន្តមានតែសហព័ទ្ធ ឬកូន  ត្រូវទទួលបាន ១០០%(មួយរយភាគរយ)[24]។

### ៤.៤.លក្ខខណ្ឌទទួលបានវិភាជន៍បូជាសព

វិភាជន៍បូជាសព សំដៅដល់ប្រាក់ឧបត្ថម្ភសម្រាប់ការចាត់ចែងបូជាសពសមាជិក **បសស**. ដែលទទួលមរណភាព ។[25]

សិទ្ធិវន្តនៃសោធនឧត្តរជីវីមានសិទ្ធិទទួលបានវិភាជន៍បូជាសព នៅពេលដែលសោធនិកជរាភាព ឬទុព្វលភាពសាមីទទួលមរណភាព។ ប្រសិនបើករណីកិច្ចនេះមិនបានបំពេញដោយសិទ្ធិវន្តនៃសោធនឧត្តរជីវី វិភាជន៍បូជាសពអាចត្រូវបនាផ្តល់ដល់ជនណាដែលជាអ្នកចាត់ចែងបូជាសព ។

លក្ខខណ្ឌទទួលបានវិភាជន៍បូជាសពត្រូវបានកំណត់ដូចខាងក្រោម ៖

- ជូនដំណឹងមក **បសស**.អំពីមរណភាព របស់សោធនិកជរាភាព ឬទុព្វលភាព ក្នុងរយៈពេលយ៉ាងយូរ០២ (ពីរ)សប្តាហ៍គិតចាប់ពីកាលបរិច្ឆេទទទួលមរណភាព ។
- បំពេញទម្រង់ស្នើសុំវិភាជន៍បូជាសព ដោយភ្ជាប់សំបុត្រមរណភាព ឬឯកសារផ្សេងៗដែលទទួលស្គាល់ដោយ **បសស**. ។

**បសស**. ត្រូវចេញសេចក្តីសម្រេចផ្តល់វិភាជន៍បូជាសព ក្នុងរយៈពេលមិនលើសពី ០២ សប្តាហ៍

---

[23] ចំណុចលេខ ៤៧ នៃឧបសម្ព័ន្ធ ច្បាប់ស្តីពី របបសន្តិសុខសង្គម ឆ្នាំ ២០១៩

[24] មាត្រា១៥ នៃអនុក្រឹត្យលេខ ៣២ អនក្រ.បក  ឆ្នាំ ២០២១

[25] ចំណុចលេខ ៣២ នៃឧបសម្ព័ន្ធ ច្បាប់ស្តីពី របបសន្តិសុខសង្គម ឆ្នាំ ២០១៩

គិតចាប់ពីកាលបរិច្ឆេទទទួលពាក្យស្នើសុំ ។[26]

### ៤.៥.លក្ខខណ្ឌទទួលបានសោធនជរាភាពអយ្យកប្បញ្ញត្តិ

សោធនជរាភាពអយ្យកប្បញ្ញត្តិ សំដៅដល់បទប្បញ្ញត្តិដើម្បីផ្តល់បុព្វសិទ្ធិពិសេសចំពោះក្រុមបុគ្គល ក្នុងពេលដែលសាមីជនត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធសោធន តាមបទបទប្បញ្ញត្តិនៃច្បាប់ស្តីពី របបសន្តិសុខសង្គម។

សមាជិក **បសស**. ដែលមានមានសិទ្ធិទទួលបានសោធនជរាភាពអយ្យកប្បញ្ញត្តិ៖

១. បានចុះបញ្ជីនៅ បសស. ផ្នែកប្រាក់សោធនចាប់ពីថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០២២ និងបានអនុវត្តបង់ប្រាក់សោធនចាប់ពីថ្ងៃទី ០១ ខែតុលា ឆ្នាំ ២០២២ ។

២.មានអាយុលើសពី ៣០(សាមសិប)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើម ដំណើរការដំបូងនៃផ្នែកប្រាក់សោធន ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០២២ ។

៣. បានបង់ភាគទានផ្នែកប្រាក់សោធន យ៉ាងតិច ២៤ (ម្ភៃបួន) ខែ ក្នុងរយៈពេល ៣៦ (សាមសិបប្រាំមួយ)ខែ គិតចាប់ពីកាលបរិច្ឆេទ នៃការចាប់ផ្តើមដំណើរការ ផ្នែកប្រាក់សោធន ។[27]

ដើម្បីបានឆ្នាំថែមអតីតភាពប្រាក់សោធន ឬឆ្នាំភាគទាន គឺយកអាយុសមាជិក **បសស**.ពេលចុះបញ្ជីផ្នែកប្រាក់សោធនដំបូង ដកនិង ៣០(សាមសិប) ចែកនិង ២ ។

ឧទាហរណ៍៖ លោក សីហា មានអាយុ ៥៦ ឆ្នាំ បានបង់ភាគទានផ្នែកប្រាក់សោធនមក**បសស**. បានរយៈពេល ០៤ ឆ្នាំជាប់គ្នា និងមានប្រាក់ឈ្នួលជាប់ភាគទាន ១ ២០០ ០០០(មួយលានពីសែន) រៀល ។

ដូ ចនេះលោក សីហា ទទួលបានអតិតភាពសម្រាប់ប្រាក់សោធនសរុបចំនួន ១៧ ឆ្នាំ មូលហេតុគឺ៖

- ចំនួន ៤ ឆ្នាំ ជារយៈពេលអតិតភាពបានបង់ភាគទានជាក់ស្តែង និង
- ចំនួន ១៣ ឆ្នាំ ទៀតបានមកពី អាយុពេលចុះបញ្ជី ៥៦ ឆ្នាំ ដក ៣០ ឆ្នាំរួចចែកនិង ០២ ។

សោធនជរាភាពអយ្យកប្បញ្ញត្តិដើម្បីផ្តល់បុព្វសិទ្ធិពិសេសនេះ បានកំណត់រយៈពេលអនុវត្ត ចន្លោះពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០២២ ដល់ ថ្ងៃទី ០១ ខែតុលា ឆ្នាំ ២០២២ ។ ករណីដែលអាចមានការលើកទឹកចិត្តបន្ថែមដល់មនុស្ស ដែលមានវ័យចាស់ ឬអាយុជិតចូលនិវត្ត ៦០ (ហុកសិប)ឆ្នាំ ប្រកាស និងលិខិតបទដ្ឋានផ្សេងទៀត និងត្រូវកំណត់អោយអនុវត្តបន្ថែមទៀត។

## ៥.ទណ្ឌកម្មរដ្ឋបាល និងទោសបញ្ញត្តិ

ទណ្ឌកម្ម រួមមាន ការពិន័យអន្តរការណ៍ ការពិន័យជាប្រាក់ ឬការផ្តន្ទាទោសដាក់ពន្ធធនាគារ។

ការពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់អគ្គនាយក បសស. ។

[26] មាត្រា១៦ នៃអនុក្រឹត្យលេខ ៣២ និងមើលលម្អិត ប្រកាសលេខ ១៦៩/២២ ក.ប/ប្រ.ក.ប.ស.ស ឆ្នាំ ២០២២

[27] មាត្រា ១០៣ នៃច្បាប់ស្តីពី របបសន្តិសុខសង្គម ឆ្នាំ ២០១៩

ការបង់ប្រាក់ពិន័យអន្តរការណ៍ នាំអោយរលត់បណ្ដឹងអាជ្ញា ។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ សំណុំរឿងបទល្មើសត្រូវបញ្ជូនទៅតុលាការដើម្បីចាត់ការតាមនីតិវិធី ។

បែបបទនិងនីតិវិធីក្នុងការពិន័យអន្តរការណ៍ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុក វិស័យរបបសន្តិសុខសង្គម ។[28]

### ៥.១.ការមិនអនុវត្តកាតព្វកិច្ចបង់ភាគទាន

និយោជក់នៃសហគ្រាស គ្រឹះស្ថានដែលមិនអនុវត្តការតព្វកិច្ចនៃការបង់ភាគទានតាមកាលកំណត់ ឬមិនអនុវត្តកាតព្វកិច្ចរាយការណ៍ ពីកម្មករនិយោជិតឲ្យបានត្រឹមត្រូវដូចមានចែងក្នុងមាត្រា ៨២(វិធានប្រតិបត្តិការងារ) នៃច្បាប់ស្ដីពីរបបសន្តិសុខសង្គម ត្រូវបង់ប្រាប់ពិន័យអន្តរការណ៍ពី ១០(ដប់)ដង ទៅ ៣០(សាមសិប)ដង នៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ ។ ការពិន័យនេះត្រូវអនុវត្តស្មើនិងចំនួនមនុស្សដែលនិយោជកបានដកយកប្រាក់ភាគទានក្នុងលក្ខខណ្ឌផ្ទុយពីបទប្បញ្ញត្តិនៃច្បាប់ របបសន្តិសុខសង្គម។[29]

### ៥.២.ការដកយកភាគទានមិនអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់

និយោជកដែលបានដកយកភាគទាន ផ្នែកហានិភ័យការងារពីប្រាក់ឈ្នួលកម្មករនិយោជិតឬបាន ដកយកភាគទានដែលជាបន្ទុករបស់ខ្លួន ដោយការកាត់យកពីប្រាក់ឈ្នួលកម្មករនិយោជិត សម្រាប់បង់ភាគទានផ្នែកថែទាំសុខភាព ផ្នែកប្រាក់សោធន ឬផ្នែកនិកម្មភាពការងារ ត្រូវផ្ដន្ទាទោសដាក់ ពន្ធនាគារ ពី ១(មួយ)ខែ ដល់ ១(មួយ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី ១២០(មួយរយម្ភៃ)ដង ទៅ ៣៦០(បីរយហុកសិប)ដង នៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ ។ ការពិន័យនេះត្រូវអនុវត្តស្មើនិងចំនួនមនុស្សដែលនិយោជកបានដកយកប្រាក់ភាគទានក្នុងលក្ខខណ្ឌផ្ទុយពីបទប្បញ្ញត្តិនៃច្បាប់ របបសន្តិសុខសង្គម។[30]

### ៥.៣.បទប្រឆាំងនឹងអធិការកិច្ចសន្តិសុខសង្គម

ត្រូវផ្ដន្ទាទោសតាមបញ្ញត្តិនៃមាត្រា ៥០៣ (បទប្រឆាំងនឹងអ្នករាជការសាធារណៈ)នៃក្រមព្រហ្មទណ្ឌចំពោះអំពើប្រឆាំងនិងការអនុវត្តមុខងាររបស់អធិការកិច្ចសន្តិសុខសង្គមដែលធ្វើសកម្មភាពដើម្បីអនុវត្តច្បាប់[31]។

## សេចក្ដីសន្និដ្ឋាន

ការអនុវត្តរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព គឺជា យន្តការពីរដែលត្រូវមានសង្គតិភាពនឹងគ្នា ដោយសារសុខភាពរបស់កម្មករនិយោជិតមិនអាចទទួលត្រឹមតែការគាំពារផ្នែកជំងឺ ឬគ្រោះ

[28] មាត្រា ៩៧ នៃច្បាប់ស្ដីពី របបសន្តិសុខសង្គម ឆ្នាំ ២០១៩

[29] មាត្រា ៩៨ នៃច្បាប់ស្ដីពី របបសន្តិសុខសង្គម ឆ្នាំ ២០១៩

[30] មាត្រា ៩៩ នៃច្បាប់ស្ដីពី របបសន្តិសុខសង្គម ឆ្នាំ ២០១៩

[31] មាត្រា ១០០ នៃច្បាប់ស្ដីពី របបសន្តិសុខសង្គម ឆ្នាំ ២០១៩

ថ្នាក់ដែលបណ្តាលមកពី ការងារប៉ុណ្ណោះទេ ប៉ុន្តែត្រូវមានការគាំពារចំពោះជំងឺ ឬគ្រោះថ្នាក់ទូទៅដែលមិនមានពាក់ព័ន្ធនឹងការងារផងដែរ។ ភាពផ្សារភ្ជាប់នៃការអនុវត្តរបបសន្តិសុខសង្គម ទាំងពីរផ្នែកនេះជាទំនាក់ទំនងដែលមានឥទ្ធិពលទៅវិញទៅមក និងផ្តល់នូវភាពពេញលេញក្នុងការគាំពារសុខភាពកម្មករនិយោជិត។ ផ្នែកនេះបាន និងកំពុង ចូលរួមចំណែកលើកកម្ពស់សុខភាពកម្មករនិយោជិត និងផ្តល់ការបង្ការជំងឺទូទៅ។

និយោជក់នៃសហគ្រាស គ្រឹះស្ថាន ជាអ្នកមានកាតព្វកិច្ចបង់ភាគទាន ផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព ។

ការសម្រេចបាននូវ ការអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន សម្រាប់កម្មករ និយោជិតវិស័យឯកជនឱ្យទទួលបានប្រាក់ចូលនិវត្តន៍ដូចទៅនឹងមន្ត្រីរាជការ ជាការទាមទារចង់បានរបស់កម្មករនិយោជិតក្នុងវិស័យឯកជន រួមជាមួយនិងការយកចិត្តទុកដាក់រៀបចំ ច្បាប់ លិខិតបទដ្ឋានពាកព័ន្ធនានា ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ។

ការបង់ភាគទានផ្នែកប្រាក់សោធន ជាកាតព្វកិច្ចរួមគ្នានិងស្មើគ្នា រវាងនិយោជក់នៃសហគ្រាស គ្រឹះស្ថាន និង កម្មករនិយោជិត ។

កម្មករនិយោជិតមិនអាចសុំបង់ភាគទានតែផ្នែកប្រាក់សោធនបានទេគឺនៅពេលចុះបញ្ជីផ្នែកប្រាក់សោធន ត្រូវបង់ភាគទានរួមគ្នាជាមួយផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព ។

បញ្ហាប្រឈមមួយចំនួននិងកើតមាននៅពេលអនុវត្តការតព្វកិច្ចទាំងឡាយ ដែលបានកំណត់ដោយច្បាប់ជាធរមាន ដោយសារការមិនបានយល់ដឹងអោយបានទូលំទូលាយ លើច្បាប់ និងបទដ្ឋានពាក់ព័ន្ធទាំងអស់នោះ។


## សេចក្តីបញ្ជាក់

អត្ថបទបង្ហាញនេះ បានធ្វើឡើងដោយមានការឧបត្ថម្ភសប្បុរសធម៌ពីប្រជាពលរដ្ឋអាមេរិក តាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID)។ មាតិកានៃបទបង្ហាញនេះជាការទទួលខុសត្រូវរបស់អង្គការ ជំនួយ ផ្នែកច្បាប់ នៃកម្ពុជា និងមិនឆ្លុះបញ្ចាំងជាចាំបាច់ពីទស្សនៈរបស់ FHI 360 ឬ USAID ឬរដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ។